FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ



ឆ្នាំទី១២ លេខ០១ ខែកក្កដា ឆ្នាំ២០១៣

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute

# ខ្យងពណ៌មាសឬខ្យងស៊ីស្រូវនិងវិធានការកម្ចាត់

## ប្រវត្តិខ្យងពណ៌មាសក្នុងប្រទេសកម្ពុជា

**ខ្យង**ពណ៌មាស (*Pomacea* sp.) មានប្រភពដើមមកពីអាមេរិកខាងត្បូងហើយត្រូវបាននាំចូលមកក្នុងតំបន់អាស៊ីដំបូងគេនៅតៃវ៉ាន់ក្នុងឆ្នាំ១៩៧៩-១៩៨០។ ខ្យងពណ៌មាសចាប់មានវត្តមាននៅក្នុងប្រទេសកម្ពុជាយើងក្នុងឆ្នាំ១៩៩២ តាមរយៈនិវត្តជនពីជំរុំតាមព្រំដែនខ្មែរ ថៃ។ ក្នុងឆ្នាំ១៩៩៥ មានការចិញ្ចឹមនិងលក់ខ្យងពណ៌មាសនេះនៅភ្នំពេញ និងឃើញវត្តមានរបស់វានៅក្នុងខេត្តយ៉ាងតិចចំនួន៩ គឺខេត្តសៀមរាប ពោធិសាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ចាម កណ្ដាល តាកែវ ព្រៃវែងនិងស្វាយរៀង។ បច្ចុប្បន្ន ខ្យងពណ៌មាសមានវត្តមាននៅក្នុងស្រែស្ទើរគ្រប់រាជធានី ខេត្តទាំងអស់នៃប្រទេសកម្ពុជា។

## ហេតុអ្វីបានជាខ្យងពណ៌មាសជាសត្វចង្រៃ ?

**ខ្យង**ពណ៌មាសជាប្រភេទខ្យងចង្រៃបំផុតដែលបំផ្លាញដំណាំស្រូវនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ខ្យងពណ៌មាសជាទូទៅស៊ីរុក្ខជាតិជាច្រើនប្រភេទមានស្លែសារាយល្អិតៗ ចកបាយទា កំប្លោក ស្មៅនិងស្លឹករុក្ខជាតិតូចៗខ្ចីទន់និងមានឱជារសដទៃផ្សេងទៀត។ នៅក្នុងស្រែ សំណាបនិងស្រូវពង្រោះដែលមានអាយុកាលពី៤–៣០ថ្ងៃ ព្រមទាំងសន្ទូងដែលនៅខ្ចីដែលទើបស្ទូងរួចរហូតដល់រយៈពេល១៥ថ្ងៃ គឺជាចំណីដ៏ឆ្ងាញ់របស់ខ្យងពណ៌មាស។ ខ្យងពណ៌មាសស៊ីកាត់ស្លឹកនិងដើមស្រូវខ្ចីៗដល់គល់។ ពួកវាអាចស៊ីបំផ្លាញដើមស្រូវខ្ចីៗក្នុងស្រែទាំងមូលក្នុងរយៈពេលមួយយប់។

**ចាប់**ពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ២០០៩ គេមិនទាន់សង្កេតឃើញថា ខ្យងពណ៌មាសនេះបំផ្លាញដំណាំស្រូវគួរឲ្យកត់សម្គាល់នោះទេ ទោះបីជាមានការព្រមានពីអ្នកបច្ចេកទេសរបស់គម្រោងកម្ពុជា អ៊ីរី អូស្ត្រាលី (CIAP) ចាប់ពីឆ្នាំ១៩៩៥ និងបានបោះពុម្ពចែកចាយព្រឹត្តប័ត្រអំពី សត្វខ្យងស៊ីស្រូវកំពុងរាតត្បាតនៅកម្ពុជា នាឆ្នាំ១៩៩៦មកក៏ដោយ លើកលែងតែលោក ថោ សុវណ្ណ អតីតនាយកអនុវិទ្យាល័យ១០មករា បឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិសាត់ បានដឹកនាំកូនសិស្សដើររើសតាមស្រែនិងស្រះយកមកស្ងោរហូបនិងកម្ទេចចោលក្នុងឆ្នាំ១៩៩៦។ ចាប់ពីឆ្នាំ២០១០មក គេសង្កេតឃើញមានការបំផ្លាញដំណាំស្រូវដោយខ្យងពណ៌មាស ហើយទំហំនៃការបំផ្លាញនេះកាន់តែមានកម្រិតធ្ងន់ធ្ងរឡើងជាលំដាប់រហូតដល់ដើមឆ្នាំ២០១៣នេះ។

## ភាពខុសគ្នារវាងខ្យងពណ៌មាសនិងខ្យងធម្មតា

| លក្ខណៈ | ខ្យងពណ៌មាស (*Pomacea* sp.) | ខ្យងធម្មតា (*Pila* sp.) |
|---|---|---|
| ពណ៌សំបក | លឿង លឿងក្រម៉ៅ ត្នោតខ្មៅ | ខ្មៅ (ជួនកាលខ្មៅលាយលឿងក្រម៉ៅ) |
| ពណ៌សាច់ខ្យង | លឿង | ខ្មៅ |
| សន្ទះ | ទន់ | រឹង |
| ពងខ្យង | ផ្កាឈូកភ្លឺឬផ្កាឈូកខ្ចី | ស |
| ចំណី | សំណាប (ស្រូវ) និងបន្លែ | ស្លែ ចកបាយទា (azolla) |



ខ្យងពណ៌មាស មានខួចគែមមាត់ធំ



ខ្យងធម្មតាមាន ខួចគែមមាត់តូច

## វដ្តជីវិតនៃខ្យងពណ៌មាស

**បន្ទាប់**ពីពងរួច សំបុកពងនីមួយៗត្រូវការរយៈពេលប្រហែល១០-១៤ថ្ងៃដើម្បីញាស់។ កូនទើបនឹងញាស់ មានសំបកទន់ឬក៏គ្មានធ្លាក់ទៅក្នុងទឹកនិង២ថ្ងៃបន្ទាប់មកសំបកក៏រឹង រួចចាប់ផ្ដើមស៊ីអាហារនៅពេលវាមានទំហំ២-៥មីលីម៉ែត្រ។ ជាទូទៅ រយៈពេលលូតលាស់ដើម្បីពេញវ័យរបស់វាគឺចាប់ផ្ដើមពី៤៥-៥៩ថ្ងៃបន្ទាប់ពីញាស់។ ក្នុងលក្ខខណ្ឌសមស្រប ខ្យងនេះអាចបន្តពូជបានក្នុងរយៈពេល៦០ថ្ងៃនិងបន្តរហូតដល់៣ឆ្នាំ។ ខ្យងពណ៌មាសអាចក្រាំងក្នុងដីបានរហូតដល់២៣០ថ្ងៃ។



**ការបន្តពូជ៖** ខ្យងពណ៌មាសមានពីរភេទ គឺភេទញីនិងភេទឈ្មោលដាច់ពីគ្នា។ ខ្យងពណ៌មាសញីនិងឈ្មោលពាក់គ្នានៅក្នុងទឹកនិងគ្រប់រដូវទាំងអស់បើសិនជាមានទឹកជាប្រចាំ ហើយការពាក់គ្នានេះមានរយៈពេលពី៣-៤ម៉ោង។ ខ្យងញីខ្លះ អាចពងបានម្តងក្នុងមួយសប្តាហ៏សម្រាប់រយៈពេល៥សប្តាហ៍ជាប់ៗគ្នា ហើយបន្ទាប់មកពួកវាអាចឈប់ពងឬអាចបន្តការពងបាន១ឬ២សំបុកពង/សប្តាហ៍។ ខ្យងញីខ្លះទៀតអាចពងបានពី២-៤សំបុកពង/សប្តាហ៍ ហើយឈប់ពងសម្រាប់រយៈពេល២ឬ៤សប្តាហ៍ ប៉ុន្តែចាប់ផ្តើមពងវិញបន្ទាប់ពីរយៈពេលនេះ។ ជាទូទៅ ខ្យងញីមួយអាចពងបាន២០០-៣០០ពងជារៀងរាល់សប្តាហ៍។ ក្នុងមួយខែវាអាចពងបានពី១០០០-១២០០ពង។ សំបុកពងនីមួយៗមានពងជាមធ្យមចំនួន៣២០ពង និងមានអត្រាញាស់ជាមធ្យមប្រមាណ៩៥%។ តាមរយៈលទ្ធផលសិក្សានៅក្នុងមន្ទីរពិសោធន៍មួយចំនួននិងការសង្កេតនៅក្នុងស្រែនៅប្រទេសហ្វីលីពិន បណ្ឌិត Ravi Joshi បានបញ្ជាក់ថា ខ្យងពណ៌មាសមិនអាចបន្តពូជឬកាត់ជាមួយខ្យងធម្មតាបានឡើយ ហើយបើពេលខ្លះមានការពាក់គ្នាមែន តែមិនមានពងឬកូនទេ។

**វិធានការការពារនិងកម្ចាត់មួយចំនួន៖** ដោយខ្យងពណ៌មាសបន្តពូជមិនរើសពេលវាលាល្ងឹកណាឲ្យតែមានទឹកដក់ក្នុងស្រែ ថ្លុក ស្រះនិងបឹង ដូចនេះការរីកសាយភាយរបស់វាមានសន្ទុះលឿនជាងខ្យងធម្មតាខ្លាំងណាស់ និងជាពិសេសចំពោះស្រែណាដែលកសិករធ្វើស្រូវ២ឬ៣ដងក្នុងមួយឆ្នាំ។ វិធានការការពារនិងកម្ចាត់ខ្យងពណ៌មាសមាន២ប្រភេទគឺ (១)ដោយមិនប្រើថ្នាំពុលកសិកម្ម និង(២)វិធានចម្រុះរួមជាមួយថ្នាំពុលកសិកម្ម។

**វិធានការការពារនិងកម្ចាត់ដោយមិនប្រើថ្នាំពុលកសិកម្ម:** វិធានការនេះ ទាមទារឲ្យកសិករធ្វើការរួមទាំងអស់គ្នានិងជាប្រចាំដើម្បីកាត់បន្ថយចំនួនខ្យងពណ៌មាសពីស្រែរបស់ខ្លួនជាបណ្តើរៗ នៅក្នុងករណីដែលកម្រិតបំផ្លាញនៅទាបជាង២០%។ វិធានទាំងនោះមាន៖

- ដាក់ព្រួលឬលួសសំណាញ់បាំងឃាំងនៅចំមុខផ្លូវទឹកហូរចេញដើម្បីកុំឲ្យកូនខ្យងនិងខ្យងពេញវ័យចូលទៅស្រែមួយទៀតបាន រួចឧស្សាហ៍ដើរប្រមូលយកទៅប្រើប្រាស់ឬកម្ទេចចោល។
- ដាក់មែកឈើឬដោតបង្គោលតូចៗនៅក្នុងស្រែ ជាពិសេសនៅគៀនភ្លឺនិងនៅកន្លែងទឹកជ្រៅឲ្យបានច្រើនដើម្បីឲ្យខ្យងឡើងមកពង រួចត្រូវដើរប្រមូលកម្ទេចចោលយ៉ាងយូរបំផុតមួយសប្តាហ៍ឲ្យបានម្តង។ បើនៅកន្លែងណាដែលពិបាកចូលទៅប្រមូល ត្រូវយកមែកឈើផ្តិះទម្លាក់ពងចូលទៅក្នុងទឹក។
- ដើររើសយកមកធ្វើម្ហូប ចំណីសត្វនិងនុយ (កណ្តុរ អន្ទង់) ឬក៏កម្ទេចចោលនាពេលព្រឹកនិងល្ងាច។
- ជាការល្អ ចូរប្រើវត្ថុទាក់ទាញខ្យងឲ្យមកប្រមូលផ្តុំងាយស្រួលក្នុងការប្រមូលដែលមានដូចជា៖ ផ្លែត្នោតទុំ ជ្រាំងខ្នុរទុំ ស្លឹកចេក ស្លឹកល្ហុងឬក្រដាសកាសែតចាស់ៗជាដើម។
- ក្នុងករណីដែលអាចបញ្ចេញទឹកពីស្រែបាន ចូរកាយចង្អូរនៅក្នុងស្រែនិងជុំវិញស្រែជិតភ្លឺជម្រៅពី៥–១០សង់ទីម៉ែត្រ ដើម្បីឲ្យខ្យងមកប្រមូលផ្តុំពេលបង្ហូរទឹកងាយស្រួលក្នុងការដើរប្រមូលចោល។
- ព្រលែងទាចូលស៊ីកូនខ្យងនាពេលសន្ទូងបែកគុម្ពនិងរឹងមាំហើយ ឬនៅពេលដែលស្រូវពង្រោះដុះលូតលាស់រឹងមាំហើយ (សូមប្រយ័ត្នចំពោះស្រូវស្រាលមិនប្រកាន់រដូវ) នៅពេលស្រែចាប់ផ្តើមដក់ទឹក៣–៤សប្តាហ៍ហើយនាពេលមុនស្ទូងឬព្រោះនិងបន្ទាប់ពីច្រូតស្រូវរួចហើយស្រែនៅមានទឹកដើម្បីឲ្យទាស៊ីកូនខ្យង។
- វិធានដែលមានប្រសិទ្ធិភាពជាងគេ គឺទិវាកម្ចាត់ខ្យងជាសហគមន៍ រួចប្រមូលធ្វើជាចំណីសត្វឬធ្វើជីកំប៉ុស្តទឹកឬក៏កម្ទេចចោល។

**វិធានចម្រុះរួមជាមួយថ្នាំពុលកសិកម្ម:** វិធានការនេះ គឺត្រូវអនុវត្តក្នុងករណីដែលខ្យងពណ៌មាសមានវត្តមានច្រើនដែលបំផ្លាញស្រូវច្រើនជាង២០%។ វិធានការនេះត្រូវអនុវត្តតាមចំណុចខាងលើរួមទាំងដាក់ថ្នាំពុលកសិកម្មប្រភេទម៉ាល់លូសាយ (Mulucide 6GB) ដែលជាថ្នាំប្រភេទនុយផលិតនៅប្រទេសវៀតណាមនិងមានលក់នៅទីផ្សារប្រទេសកម្ពុជាដាក់ជាកញ្ចប់ទម្ងន់១គីឡូក្រាម ដោយមិនទាន់មានបិទស្លាកជាភាសាខ្មែរនៅឡើយ។ តាមលទ្ធផលពិសោធន៍ជាច្រើនដងរបស់កាឌីបានបង្ហាញថា ការប្រើប្រាស់ថ្នាំម៉ាល់លូសាយតាមកម្រិតណែនាំគឺ១០គីឡូក្រាម/ហតមិនបណ្តាលឲ្យប៉ះពាល់ដល់កង្កែប ក្តាម កំពឹសនិងត្រីស្រែឡើយ។ **ត្រូវចងចាំថា ជម្រៅទឹកសមស្របសម្រាប់បាចគឺពី៣–៥សង់ទីម៉ែត្រ ព្រោះជម្រៅទឹកជ្រៅជាងនេះមិនសមប្រកបសម្រាប់ខ្យងស៊ីចំណី ហើយថ្នាំនុយក៏ឆាប់រលាយផងដែរ។** ចូរប្រើប្រាស់ថ្នាំម៉ាល់លូសាយតាមប្រព័ន្ធដាំដុះដំណាំស្រូវដូចរបៀបខាងក្រោម៖

- ចំពោះស្រូវវស្សា: ត្រូវបាចនៅពេលភ្លៀងដើមឆ្នាំបន្ទាប់ពីស្រែចាប់ផ្តើមដក់ទឹកដំបូង។ បើសង្កេតឃើញវត្តមានរបស់ខ្យងពណ៌មាសនៅតែច្រើនពេលស្ទូងឬព្រោះ ត្រូវបាចថ្នាំនុយម្តងទៀតបន្ទាប់ពីស្ទូងឬព្រោះហើយ។
- ចំពោះស្រូវបង្កើនរដូវ: ត្រូវបាចថ្នាំនៅពេលដាក់ទឹកស្រែសម្រាប់ភ្ជួរដាស់ដីដាំស្រូវដើមរដូវ តែបើនៅពេលស្ទូងឬព្រោះហើយនៅតែមានច្រើន ត្រូវបាចថ្នាំនុយម្តងទៀត។ គួរបាចថ្នាំនុយម្តងទៀតដែរបន្ទាប់ពីស្ទូងឬព្រោះស្រូវចុងរដូវរួច ក្នុងករណីវត្តមានខ្យងពណ៌មាសនៅតែមានច្រើន។
- ចំពោះស្រូវប្រដេញទឹក: ត្រូវបាចថ្នាំនុយនៅពេលដាក់ទឹកស្រែលើកទី១បន្ទាប់ពីស្រូវពង្រោះដុះបាន៥–១០សង់ទីម៉ែត្រ។ ក្នុងករណីស្ទូង បន្ទាប់ពីស្ទូងរួច ត្រូវរង់ចាំទឹកក្នុងស្រែស្រកមកដល់៣–៥សង់ទីម៉ែត្រ ទើបបាចថ្នាំនុយ។
- ស្រូវមុនទឹកចូល: ត្រូវបាចថ្នាំនៅពេលដាក់ទឹកស្រែសម្រាប់ភ្ជួរដាស់ដីលើកទី១ ហើយបើនាពេលស្ទូងឬព្រោះខ្យងពណ៌មាសនៅតែមានច្រើន ត្រូវបាចថ្នាំនុយម្តងទៀត។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យការពារដំណាំ មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការនិងពាណិជ្ជកម្មនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្ខរ: plab@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh